# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៣៥៣ MIH / ២០១៧

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការវាយតម្លៃទទួលស្គាល់អចិន្ត្រៃយ៍

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
## និងជាប្រធានក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ៤៣៥ MIH / 2014 ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់
- បានឃើញប្រកាសលេខ ៥២៣ MIH / 2014 ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់
- បានឃើញប្រកាសលេខ ១៦១ MIH / 2015 ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ចរបស់នាយកដ្ឋានវាយតម្លៃ- ទទួលស្គាល់
- យោងតាមស្មារតីអង្គប្រជុំក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់លើកទី២ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧

## សម្រេច

**ប្រការ១.**_

ត្រូវបានបង្កើតគណៈកម្មការវាយតម្លៃទទួលស្គាល់អចិន្ត្រៃយ៍ Permanent Accreditation Committee (PAC) ដែលមានសមាសភាពដូចខាងក្រោម ៖



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com

| | | |
|---|---|---|
| ១- ឯកឧត្តម **គង់ វង្សា** | ប្រធានផ្នែកស្រាវជ្រាវ និងវិភាគគោលនយោបាយសេដ្ឋកិច្ច តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត **នុត សម្បត្តិ** | ប្រធានវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម តំណាងរាជ្យបណ្ឌិតសភាកម្ពុជា | អនុប្រធាន |
| ៣- លោក សាស្ត្រាចារ្យ **ឈាង សេនា** | ព្រឹទ្ធបុរសមហាវិទ្យាល័យឱសថសាស្ត្រ តំណាងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ៤- លោក **ភីម មុនីសេដ្ឋា** | អគ្គលេខាធិការសមាគម តំណាងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា | សមាជិក |
| ៥- លោក **ថោង វង្សី** | សាស្ត្រាចារ្យដេប៉ាតឺម៉ង់គីមី តំណាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |

**ប្រការ២._**

គណៈកម្មការវាយតម្លៃទទួលស្គាល់អចិន្ត្រៃយ៍ មានភារកិច្ចដូចតទៅ៖

- ពិនិត្យមើលរបាយការណ៍វាយតម្លៃទទួលស្គាល់ ដើម្បីផ្តល់មតិមកនាយកដ្ឋានវាយតម្លៃទទួលស្គាល់អំពីការយល់ឃើញរបស់ខ្លួន ទាក់ទិននឹងការងារវាយតម្លៃទទួលស្គាល់ ដល់អង្គភាពវាយតម្លៃភាពអនុលោម Conformity Assessment Bodies (CABs)
- ធ្វើសំណើ មកប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដើម្បីផ្តល់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ការបដិសេធ ឬការដកហូត វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់
- សហការ និងគាំទ្រដល់ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ ក្នុងករណីមានការតវ៉ាប្រឆាំងទៅនឹងការសម្រេចរបស់ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់។

**ប្រការ៣._**

គណៈកម្មការវាយតម្លៃទទួលស្គាល់អចិន្ត្រៃយ៍ ត្រូវចូលរួមប្រជុំឲ្យបានទៀងទាត់តាមការអញ្ជើញរបស់ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដែលជាសមាជិកអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបានលុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិកសរុប។ រាល់សេចក្តីសម្រេចណាមួយនៃអង្គប្រជុំរបស់គណៈកម្មការវាយតម្លៃទទួលស្គាល់អចិន្ត្រៃយ៍ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃសមាជិកវត្តមានក្នុងកិច្ចប្រជុំ។ នៅពេលប្រធានអវត្តមាន កិច្ចប្រជុំអាចដំណើរការទៅបានក្រោមការដឹកនាំរបស់អនុប្រធាន។ ក្នុងករណីអវត្តមានប្រធាន និងអនុប្រធាន ការប្រជុំត្រូវដឹកនាំដោយសមាជិកតំណាងណាម្នាក់ដែលបានទទួលការប្រគល់សិទ្ធិពីសមាជិកមានវត្តមានក្នុងពេលប្រជុំ។

**ប្រការ៤._**

សមាសភាពគណៈកម្មការវាយតម្លៃទទួលស្គាល់អចិន្ត្រៃយ៍ ត្រូវចុះហត្ថលេខាលើកិច្ចសន្យា និងទម្រង់រក្សាការសម្ងាត់ (Confidential Form) តាមក្បួននៃប្រព័ន្ធគ្រប់គ្រងគុណភាព Quality Management System (QMS) របស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់។

**ប្រការ៥._**

គណៈកម្មការវាយតម្លៃទទួលស្គាល់អចិន្ត្រៃយ៍ មាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ជាលេខាធិការដ្ឋានធ្វើការសម្របសម្រួលរាល់ការងារទាំងអស់នៃគណៈកម្មការវាយតម្លៃទទួលស្គាល់អចិន្ត្រៃយ៍។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

**ប្រការ៦.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧.**_

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ គ្រប់អង្គភាពពាក់ព័ន្ធ និងសមាសភាពគណៈកម្មការដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**និងជាប្រធានក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់**

**ចម ប្រសិទ្ធ**

**__កន្លែងទទួល__ ៖**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់
  *«ដើម្បីជូនជ្រាប»*
- ដូចប្រការ៧ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com